GMAC

Garment Manufacturers Association in Cambodia

# លិខិតអំពាវនាវដល់អ្នកបញ្ជាទិញទាំងអស់ដែលទិញសម្លៀកបំពាក់ ស្បែកជើង និង ផលិតផលធ្វើដំណើរពីកម្ពុជា

កម្ពុជាជាប្រទេសទីមួយក្នុងពិភពលោកដែលភ្ជាប់ពាណិជ្ជកម្មទៅនឹងស្តង់ដារការងារ។ នៅឆ្នាំ២០០១ យើងបានចាប់ដៃគូជាមួយអង្គការអន្តរជាតិខាងការងារ (ILO) ហើយបានចាប់ផ្តើមកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) ដែលតម្រូវឲ្យរោងចក្រនាំចេញសម្លៀកបំពាក់ទាំងអស់ក្នុងប្រទេសកម្ពុជាស្ថិតនៅក្រោមការត្រួតពិនិត្យពី ILOដើម្បីធានាអនុលោមភាពទៅតាមច្បាប់ជាតិនិងស្តង់ដារការងារអន្តរជាតិ ហើយកម្មវិធីនេះត្រូវបានអនុវត្តរហូតមកដល់បច្ចុប្បន្ន។ យើងមានមោទនភាពចំពោះកេរដំណែលនេះ ហើយនឹងបន្តធានាថាសិទ្ធិការងារនិងសិទ្ធិសង្គមរបស់កម្មករយើងត្រូវបានលើកកម្ពស់ ខណៈយើងបង្កើតចង្វាក់ផ្គត់ផ្គង់បីភាពមួយ។

ចាប់តាំងពីការអំពាវនាវរបស់យើងកាលពីមុនទៅអ្នកបញ្ជាទិញទាំងអស់កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ យើងទទួលបានការប្តេជ្ញាចិត្តពីអ្នកបញ្ជាទិញមួយចំនួន ដែលសមាគម(GMAC) និងប្រជាជនកម្ពុជាមានការដឹងគុណ ប៉ុន្តែស្ថានភាពចាប់តាំងពីពេលនោះមកកាន់តែអាក្រក់ជាសកល និងជាពិសេសក្នុងប្រទេសកម្ពុជា។

គិតត្រឹមពេលសរសេរលិខិតនេះ រោងចក្រចំនួន១៨០បានព្យួរប្រតិបត្តិការរបស់ខ្លួន ហើយរោងចក្រចំនួន៦០បន្ថែមទៀតនឹងឈានទៅរកការព្យួរផងដែរ ដែលកំពុងប៉ះពាល់ដល់កម្មករជាង១៥០.០០០នាក់ដែលត្រូវបានព្យួរការងារជាបណ្តោះអាសន្នរហូតមកដល់ពេលនេះ ដោយមិនដឹងច្បាស់លាស់ថានឹងបន្តការងារវិញនៅពេលណា ហើយកម្មករជិត២០០.០០០នាក់នឹងត្រូវព្យួរការងារនាពេលខាងមុខឆាប់ៗនេះ ដែលនឹងប៉ះពាល់មិនត្រឹមតែកម្មករនោះទេ ប៉ុន្តែថែមទាំងសមាជិកគ្រួសារប្រមាណ២លាននាក់ដែលពឹងផ្អែកលើពួកគេ។

យើងយល់អំពីភាពលំបាកដែលអ្នកបញ្ជាទិញកំពុងប្រឈមមុខ ប៉ុន្តែយើងពិតជាអំពាវនាវយ៉ាងខ្លាំងទៅអ្នកបញ្ជាទិញទាំងអស់មេត្តាគោរពតាមលក្ខខណ្ឌទូទាត់ប្រាក់សម្រាប់ទំនិញដែលបានទទួលរួចហើយ និង/ឬដែលកំពុងដឹកទៅឲ្យអ្នកបញ្ជាទិញ។ រោងចក្រនៅកម្ពុជាកំពុងរងគ្រោះរួចហើយពីការលុបចោលការបញ្ជាទិញជាច្រើននិងការគ្មានបញ្ជាទិញថ្មីៗ ហើយមិនអាចទ្រាំទ្រនឹងការមិនទូទាត់ប្រាក់នោះទេ។

ខណៈផលិតផលកំពុងត្រូវបានធ្វើការនាំចេញ រោងចក្ររបស់យើងត្រូវតែទទួលបានការទូទាត់នូវអ្វីដែលត្រូវបានជំពាក់ ហើយការផ្តល់អ្វីតិចជាងនេះគឺមិនត្រឹមត្រូវនោះទេ។

លក្ខខណ្ឌទូទាត់ប្រាក់អាចពិភាក្សាគ្នាបាន ប៉ុន្តែការមិនទូទាត់គឺមិនអាចទទួលយកបានទេ។ ហេតុដូច្នេះ យើងសូមអំពាវនាវដល់អ្នកបញ្ជាទិញទាំងអស់មេត្តាទូទាត់បំណុលរបស់ខ្លួន។



សមាគមរោងចក្រកាត់ដេរនៅកម្ពុជា Garment Manufacturers Association in Cambodia សមាគមរោងចក្រកាត់ដេរនៅកម្ពុជា Garment Manufacturers Association in Cambodia

តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Phum Trapeang Kul, Sangkat Kantouk, Khan Por Sen Chey, Phnom Penh, Cambodia.
Tel: (855) 23-301 181 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org

តាងនាមឲ្យរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងកម្មករទាំងអស់នៅក្នុងវិស័យទាំងនេះ យើងសូមថ្លែងអំណរគុណដល់អ្នកបញ្ជាទិញទាំងអស់ចំពោះការគាំទ្រនិងទំនុកចិត្តដែលបានបង្ហាញនិងផ្តល់ឱ្យយើងក្នុងរយៈកាល២ទសវត្សរ៍កន្លងមកនេះ។ យើងទន្ទឹងរង់ចាំកិច្ចសហការច្រើនឆ្នាំបន្ថែមទៀតជាមួយអ្នកបញ្ជាទិញទាំងអស់ដោយស្មោះ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា